ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៩-១១-២០១៦ -ព្រះរាជក្រម នស/រកម/១១១៦/០១៤ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ៩៤៧១


### ២~ព្រះរាជក្រឹត្យ


០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី និងព្រះសង្ឃ ចំនួន ៨៨ រូប/អង្គ ៩៤៨២

០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ៩៤៨៤

០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្តមនាវី និងថ្នាក់វរនាវី នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៥ រូប ៩៤៨៥

០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៦ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **ជី សាន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩៤៨៧

០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហាន លូយូ** (HAN LUYOU) ជនជាតិចិន សញ្ជាតិចិន ៩៤៨៨

០៨-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ី ឈួយហុង** (XU CUIHONG) ជនជាតិចិន សញ្ជាតិចិន ៩៤៨៩

១០-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/៩៩៩ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះ សពឯកឧត្តម **ពេជ កែវ** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៩៤៩០

១០-១១-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១១១៦/១០០០ ស្តីពី ការតែងតាំងឯកឧត្តម **សុខ សូកេន** ជាអនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៩៤៩១

# II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

០៤-១១-២០១៦ -អនុក្រឹត្យលេខ ១០៦៩ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៩៤៩២

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៩៤៩៣

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៤ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៩៤៩៤

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៩៤៩៥

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៩៥០៤

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៧ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៩៥០៩

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥១០

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៤៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៥១២

២៥-១១-២០១៦ -អនុក្រឹត្យលេខ ១១៥០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៥១៧

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-១០-២០១៦ -ប្រកាសលេខ ១២៨២ សហវ.ប្រក ស្តីពី សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ៩៥១៩

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

១១-១១-២០១៦ -ប្រកាសលេខ ៥៨៣ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រ៉ុន ឆេស្ទ័រ អ៊ីន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៥៣៧

១១-១១-២០១៦ -ប្រកាសលេខ ៥៨៤ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តៃគី (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងសំអាង ៩៥៤០

១៨-១១-២០១៦ -ប្រកាសលេខ ៥៨៨ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អារ៉ាំនខេម ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៥៤៣

១៨-១១-២០១៦ -ប្រកាសលេខ ៥៨៩ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើ ដេវើរ អិនធើណេសិនណល ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៩៥៤៦

# ព្រះរាជក្រម

នស/រកម/១១១៦/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ
# វិស័យសុខាភិបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាព និងសុវត្ថិភាពរបស់ប្រជាជនតាមរយៈ ការផ្តល់នូវយន្តការក្នុងការធានាថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មានគុណវុឌ្ឍិ សមត្ថភាព និងសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ សុខាភិបាល និងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

**អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍សុខាភិបាល អ្នកព្យាបាលដោយចលនា ទន្តគិលានុបដ្ឋាក អ្នកបច្ចេកទេសវិទ្យុសាស្ត្រ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលទទួលបានការចុះ បញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

**អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួល បានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ។

**ការប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ការអនុវត្តវិជ្ជាជីវៈដែលស្ថិតនៅក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ។

**បញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល** សំដៅដល់បញ្ជីគណៈគ្រូពេទ្យកម្ពុជា បញ្ជីគណៈទន្តពេទ្យកម្ពុជា បញ្ជីគណៈឱសថការីកម្ពុជា បញ្ជីគណៈឆ្មបកម្ពុជា បញ្ជីគណៈគិលានុបដ្ឋាកកម្ពុជា និងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលផ្សេងៗទៀត ដែលមានកំណត់ត្រានៃឈ្មោះ និងព័ត៌មានផ្សេងៗរបស់អ្នកវិជ្ជាជីវៈសុខាភិបាលនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល តាមបញ្ញត្តិនៃច្បាប់នេះ ហើយបញ្ជីនេះត្រូវគ្រប់គ្រងដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**ការចុះបញ្ជិកា** សំដៅដល់ដំណើរការនៃការចុះបញ្ជីបុគ្គលម្នាក់ទៅជាអ្នកវិជ្ជាជីវៈសុខាភិបាល ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈសុខាភិបាល ដែលផ្តល់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ បន្ទាប់ពីមានការចុះបញ្ជិកា និងការបំពេញលក្ខខណ្ឌ ដើម្បីទទួលបានអាជ្ញាបណ្ណស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

**កំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល** សំដៅដល់រាល់កំហុសឆ្គងទាំងឡាយដែលខុសនឹង ក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និយាមវិជ្ជាជីវៈ និងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ដោយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.-

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗមានសមត្ថកិច្ចក្នុងការចុះបញ្ជិកានិងផ្តល់អាជ្ញា បណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ព្រមទាំងគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បទប្បញ្ញត្តិស្តីពីបទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

## ជំពូកទី ៣
## ការប្រកបវិជ្ជាជីវៈសុខាភិបាល

### មាត្រា ៦.-

បុគ្គលទាំងឡាយដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-ចុះបញ្ជិកាក្នុងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

### មាត្រា ៧.-

ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដែលមានសុពលភាព

-គោរពក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ

-អនុវត្តការងារក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ។

### មាត្រា ៨.-

បុគ្គលដែលអាចស្នើសុំចុះបញ្ជិកា ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

-មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

-មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- មិនមានបញ្ហាសុខភាពខាងផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន
- ការស្នើសុំចុះបញ្ជិកាត្រូវធ្វើនៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការចុះបញ្ជិកា ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ៩.-**

អ្នកវិជ្ជាជីវៈសុខាភិបាលដែលអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

- បានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ
- រក្សាបាននិយាមតម្រូវសម្រាប់សមត្ថភាពក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល
- បង្ហាញថាមានបច្ចុប្បន្នភាពសមត្ថភាព ឬបទពិសោធថ្មីៗដែលច្បាប់តម្រូវសម្រាប់ការប្រកបវិជ្ជាជីវៈ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ នៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ
- មិនមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវធ្វើនៅគណៈវិជ្ជាជីវៈ សុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ១០.-**

លក្ខខណ្ឌ និងនីតិវិធីក្នុងការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវកំណត់ដោយ គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១១.-**

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំចុះបញ្ជិកា និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល នៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធណាមួយស្របតាមមុខវិជ្ជាជីវៈរបស់ខ្លួន ។

**មាត្រា ១២.-**

ដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ត្រូវកំណត់ដោយគណៈ-វិជ្ជាជីវៈ សុខាភិបាលដែលពាក់ព័ន្ធដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៤

## សម្បទាក្នុងការប្រកបវិជ្ជាជីវៈ

**មាត្រា ១៣.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលអាចត្រូវបានចាត់ទុកថាមិនមានសម្បទាក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល ប្រសិនបើ ៖

- មិនបានបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលដែលកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ
- បានប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាល ដែលនាំទៅដល់ការផ្អាកអាជ្ញាបណ្ណវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាស្ថាពរ
- មានការបញ្ជាក់ថាមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន ឬ
- ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ ។

**មាត្រា ១៤.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ អាចធ្វើការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលបានគ្រប់ពេលវេលា ។

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ត្រូវធ្វើការពិនិត្យរាល់បណ្តឹង ឬការរាយការណ៍ដែលពាក់ព័ន្ធនឹងសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បែបបទ នីតិវិធី និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងការពិនិត្យរាល់បណ្តឹង ឬការរាយការណ៍ខាងលើ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

## ជំពូកទី ៥
## ទណ្ឌកម្មខាងវិន័យ និងបណ្ដឹងតវ៉ា

**មាត្រា ១៥.-**

ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈ គណៈវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ អាចដាក់ទណ្ឌកម្មខាងវិន័យដូចខាងក្រោម ៖

- ធ្វើការព្រមាន
- ធ្វើការកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន
- កំណត់លក្ខខណ្ឌផ្សេងៗចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងរយៈពេលកំណត់ណាមួយ ឬជាស្ថាពរ
- ផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន
- ដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាស្ថាពរ
- លុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

លក្ខណវិនិច្ឆ័យក្នុងការអនុវត្តទណ្ឌកម្មខាងវិន័យ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១៦.-**

ចំពោះរាល់បណ្តឹងទាក់ទងនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ភាគីពាក់ព័ន្ធ មានសិទ្ធិប្តឹងជាមុនទៅគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

នីតិវិធីលើបណ្តឹងពាក់ព័ន្ធនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

រាល់ការវិនិច្ឆ័យ និងនីតិវិធីរបស់តុលាការ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ចាំបាច់ត្រូវមានការចូលរួមពីគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១៨.-**

គណៈវិជ្ជាជីវៈសុខាភិបាល អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលបណ្តោះអាសន្នជាបន្ទាន់ ក្នុងករណីដែលមានហេតុផលសមស្របសង្ស័យថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលណាម្នាក់

បានប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាល ដែលនាំឲ្យប៉ះពាល់ដល់ជីវិតមនុស្ស ហើយដែលអាចបន្តបង្កគ្រោះថ្នាក់ដល់អ្នកផ្សេងទៀត ។

**មាត្រា ១៩.-**

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ក្នុងករណីណាមួយដូចខាងក្រោម ៖

- មានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- នៅតែប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈធ្លាប់ព្រមាន រួចហើយ ឬប្រព្រឹត្តខុសនឹងលក្ខខណ្ឌតម្រូវផ្សេងៗ
- ក្នុងករណីផ្សេងទៀតដែលគណៈវិជ្ជាជីវៈសុខាភិបាល រកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

បុគ្គលដែលត្រូវបានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗសម្រេចផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន អាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលឡើងវិញ ដោយអនុលោមទៅតាមលក្ខខណ្ឌ និងនីតិវិធីដែលត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ២០.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធត្រូវលុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល និងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងឡាយណាដែលត្រូវបានតុលាការសម្រេចជាស្ថាពរថាមានទោសពីបទឧក្រិដ្ឋ ឬត្រូវបានតុលាការហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាអចិន្ត្រៃយ៍ ។

**មាត្រា ២១.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មខាងវិន័យ ដែលធ្វើឡើងដោយគណៈ-វិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចនោះ ។

**មាត្រា ២២.-**

ការទទួលរងទណ្ឌកម្មខាងវិន័យ មិនអាចធ្វើឲ្យអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រព្រឹត្តខុសរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬ/និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។

## ជំពូកទី ៦
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២៣.-**

ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៤.-**

ការគ្រប់គ្រងអ្នកប្រកប វិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈរបស់ខ្លួន ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ២៥.-**

ជនណាដែលបានក្លែងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ២៦.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះជនណាដែលមិនមែនជាអ្នក វិជ្ជាជីវៈសុខាភិបាល ហើយបានប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៧.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធនីមួយៗបានផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ហើយនៅតែប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៨.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកវិជ្ជាជីវៈសុខា-ភិបាលដែលប្រកប វិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៩.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលអស់សុពលភាព ។

**មាត្រា ៣០.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយរំលោភបំពានដែនកំណត់វិជ្ជាជីវៈសុខាភិបាល ឬបំពានលើលក្ខខណ្ឌដែលបានកំណត់ចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាល ។

ករណីដែលទទួលរងការពិន័យម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលត្រូវ ផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣១.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មការមួយដែលរួមមានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ និងនាយកដ្ឋានដែលពាក់ព័ន្ធនៃក្រសួងសុខាភិបាល ។ប្រធាននៃគណៈកម្មការនេះ គឺជារដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ។

ការរៀបចំ និងលក្ខខណ្ឌប្រតិបត្តិរបស់គណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

គណៈកម្មការនេះ មានភារកិច្ចណែនាំ និងដឹកនាំដើម្បីសម្របសម្រួល ក្នុងការកសាងសមត្ថភាពរបស់គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ ដើម្បីបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ដំបូងនៃការអនុវត្តច្បាប់នេះ គណៈវិជ្ជាជីវៈសុខាភិបាលអាចទទួលបាននូវថវិកាប្រតិបត្តិប្រចាំឆ្នាំពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីបំពេញតួនាទីនិងភារកិច្ច ដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣២.-**

រាល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលការចុះបញ្ជិកានៅមានសុពលភាពមុនពេលច្បាប់នេះចូលជាធរមាន នៅបន្តសុពលភាពក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៣.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន អ្នកវិជ្ជាជីវៈសុខាភិបាលមានរយៈពេល ១២ (ដប់ពីរ) ខែយ៉ាងយូរ ដើម្បីមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៤.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល នៅបន្តអនុវត្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៦១១.១០៧៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខៈ១០៦៧ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/៩៧៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

១-ឯកឧត្តម **ផៃ ម៉ិនវណ្ណៈ**
២-លោកជំទាវ **ប្រាក់ ច័ន្ទសុខា**
៣-ឧត្តមសេនីយ៍ត្រី **ឈឿន សុចិត្ត** អត្តលេខ៥៣៨៤៩
៤-ឧកញ៉ា **ណាង សុធី**

**ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ព្រះតេជគុណ **អ៊ុំ ម៉ិនឈឿន**
២- ឧត្តមសេនីយ៍ត្រី **សយ សារ៉ាត់** អត្តលេខ០១២០៧
៣- លោក **សាយ កុយ**
៤- លោក **នុត លី**
៥- លោក **វណ្ណៈ សោភានិត**
៦- លោក **យូ ដាណាង**
៧- លោក **ដូ សុខ**
៨- លោក **សុធី សុវិត្យា**
៩- លោក **ម៉ាង ម៉ាងតារា**
១០- លោក **សែន សឿន**
១១- លោក **សារឹម វុទ្ធី**

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- វរៈនាវីឯក **ចាន់ រិទ្ធ** អត្តលេខ ០៣១០២៨
២- លោក **នុយ សឿន**
៣- វរៈនាវីទោ **អឿ សារឿន** អត្តលេខ ០៣០៩៩៦
៤- វរសេនីយ៍ត្រី **តេង គីស៊ាន** អត្តលេខ ០៣០៤៤
៥- លោក **ពេជ្រ ចន្ថា**
៦- លោក **ជា សារ៉ាត់**
៧- លោក **វ៉ាន់ ទ្រីវចិញ**
៨- លោកស្រី **ស៊ុន នាង**

**ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ **អឿ វ៉ាន់ថា**
២- លោកជំទាវ **សំរិត សោភ័ណ្ឌនារី**
៣- វេជ្ជបណ្ឌិត **ថោង រ៉ា**
៤- លោក **ម៉ុន ពីន**
៥- លោកជំទាវ **ហែម សាមុត**
៦- ឧកញ៉ា **កែវ មុំ**
៧- លោកជំទាវ **សៅ ស្រីពៅ**
៨- លោក **ញ៉ិប វណ្ណនី**
៩- លោក **អ៊ុត ម៉ិនលី**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោក ឡូ ម៉ុនរ៉ា
២- លោក យា ម៉ុនណា
៣- លោក សុខ ស្រេង
៤- លោកស្រី លី ឡៀង
៥- លោក អ៊ែតជា ជូរ៉ាមី
៦- លោកស្រី ជា សៀងហ៉ា
៧- លោកស្រី ជា សៀកហេង
៨- លោកស្រី ជា ឡៃស៊ាង
៩- លោកស្រី ជា ប៉ូលីន
១០- លោក គង់ សារ៉ាយ
១១- វរៈសេនីយ៍ត្រី ភា សារ៉ាន់ អត្តលេខ១៤៨៥១
១២- អនុសេនីយ៍ឯក ជួង នី អត្តលេខ០១៧២៤៤
១៣- អនុសេនីយ៍ឯក កែវ តិរុណា អត្តលេខ១៨២៣១
១៤- អនុសេនីយ៍ទោ តូច ចន្នី អត្តលេខ២៤២៥៣
១៥- អនុសេនីយ៍ទោ ហ៊ីយសាខុន អត្តលេខ២៣៧១៤
១៦- អនុសេនីយ៍ទោ ហួនសុផល អត្តលេខ៥៩៨១
១៧- អនុសេនីយ៍ទោ ហួន សុផាត អត្តលេខ៧១០១៩
១៨- លោក សាន់ បូរិទ្ធ

**ច-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :**

១- លោកស្រី សេង តក្កនារី
២- លោកស្រី ប៉ុក ណាណ្ណា
៣- លោកស្រី សុខ ចិន្តា
៤- លោកស្រី ភ្លេ ចិន្តា

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- លោក គ្រុយ រតនា
០២- លោក កែវ សារិន
៣- លោកស្រី គុយ ម៉ាលី
៤- លោក សេន រ៉ែន
៥- លោក វណ្ណៈ សោភានេត្រ
៦- លោកស្រី សៅ ចណ្ណា
៧- អនុសេនីយ៍ឯក យឿង សុខា អត្តលេខ២៣៤៦០
៨- អនុសេនីយ៍ឯ សុខ ហួង អត្តលេខ៥៦២៩១
៩- អនុសេនីយ៍ទោ ឌីម រដ្ឋា អត្តលេខ៥៥៧៣២
១០- អនុសេនីយ៍ទោ តិន សារ៉ាវុធ អត្តលេខ៥៥៤៩០
១១- អនុសេនីយ៍ទោ ស៊ុន ឯក អត្តលេខ៤២២៣
១២- លោកស្រី អៀត ធីរៈ អត្តលេខ៥៩៨៧៤
១៣- អនុសេនីយ៍ត្រី ឧត្ស តូស្ដេត្រ អត្តលេខ៤១៩៧
១៤- អនុសេនីយ៍ត្រី ទីម ទេ អត្តលេខ៥៩៨០
១៥- អនុសេនីយ៍ត្រី ហួរ តៃឆេង អត្តលេខ៧៦១០១
១៦- ព្រិន្ទបាលទោ អ៊ុន មឿន អត្តលេខ៥៩៩២
១៧- ព្រិន្ទបាលទោ ម៉ូ សុតវណ្ណ អត្តលេខ៧១០៣៩
១៨- ពលបាលឯក ទេព ណារិនអត្តលេខ៥៩៩១៥
១៩- លោក ឡេង គុណា

**ជ-គ្រឿងឥស្សរិយយស ការពារជាតិថ្នាក់ សំរឹទ្ធ ប្រាក់ និងថ្នាក់មាស :**

១- អនុសេនីយ៍ឯក ជួង នាម អត្តលេខ១៨២២៩
២- អនុសេនីយ៍ឯក យោង ម៉ុង អត្តលេខ០១៨១៩៩
៣- អនុសេនីយ៍ទោ ញ៉ែម រស្មី អត្តលេខ៧១០១៨
៤- អនុសេនីយ៍ទោ មន ចន្ថា អត្តលេខ៥៩៨៧៧
៥- អនុសេនីយ៍ទោ ស៊ិន ជឿន អត្តលេខ៧១០២២
៦- អនុសេនីយ៍ទោអ៊ុង ផល អត្តលេខ៥៩៨២៦
៧- អនុសេនីយ៍ត្រី ស៊ុន គេ អត្តលេខ៧៧១០០
៨- ព្រិន្ទបាលឯក ទី ណារ៉ា អត្តលេខ៧១០២៣
៩- ព្រិន្ទបាលឯក លឹម អាន អត្តលេខ៤២៣៨១
១០-ព្រិន្ទបាលទោ មាស សំអាត អត្តលេខ៥៩៩១៣

**ឈ-គ្រឿងឥស្សរិយយស ថ្នាក់ សេនាជ័យសិទ្ធ :**

១- វរសេនីយ៍ឯក ព្រុំ សារ៉ុន អត្តលេខ០០៩៥៥
២- វរសេនីយ៍ឯក សាមិន វិបុល អត្តលេខ០១៥៥១៨
៣- វរសេនីយ៍ត្រី ហ៊ួត ចាន់ធី អត្តលេខ២៣៧៨៥
៤- អនុសេនីយ៍ឯក ទូច សទ្ធា អត្តលេខ០១០៦៨១
៥- អនុសេនីយ៍ឯក ទេពណារិទ្ធ អត្តលេខ៦១៤៦១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល/. ១៦១១-១០០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

លេខៈ ៩៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/៩៩៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

-ឧត្តមសេនីយ៍ត្រី **អ៊ឹម សារ៉ា** អត្តលេខ ០០៨៨៦៣

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ញូង ហោលី** អត្តលេខ ០១៧៧៨៧

២-វរសេនីយ៍ឯក **ហេង សុធា** អត្តលេខ ០៣៦៨៥០

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរស.១៦១១-១០០៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

លេខ: ៩៩២ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/ ៩៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមនាវី និងថ្នាក់វរនាវី នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមនាវីទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមនាវីត្រី | **នុច** | **ស៊ីដេត** | អត្តលេខ ០១០២៨៥ |
| ២-ឧត្តមនាវីត្រី | **កែម** | **ស៊ូកា** | អត្តលេខ ០០១៨៣៨ |
| ៣-ឧត្តមនាវីត្រី | **សៅ** | **សុផល** | អត្តលេខ ០១៥០៧៦ |

**ខ-ឋានន្តរស័ក្តិឧត្តមនាវីត្រី**

| | | | |
|---|---|---|---|
| ១-វរនាវីឯក | **ហ៊ីង** | **ចាន់ថុល** | អត្តលេខ ០១០២៦៩ |
| ២-វរនាវីឯក | **ទេព** | **សំអុល** | អត្តលេខ ០១០២៩៧ |
| ៣-វរនាវីឯក | **យឿង** | **ឃិន** | អត្តលេខ ០១០២៧៥ |
| ៤-វរនាវីឯក | **សាន់** | **ដារ៉ា** | អត្តលេខ ០១៥១០៧ |
| ៥-វរនាវីឯក | **ស៊ូ** | **សុខេន** | អត្តលេខ ០៣១០៥៧ |
| ៦-វរនាវីឯក | **ឱ** | **គន** | អត្តលេខ ០១៥១១៨ |
| ៧-វរនាវីឯក | **ពុត** | **ឌី** | អត្តលេខ ០១០៣០០ |
| ៨-វរនាវីឯក | **ម៉ែន** | **ខុន** | អត្តលេខ ០១៥១១៩ |
| ៩-វរនាវីឯក | **អ៊ិន** | **សុខេមរា** | អត្តលេខ ០៣១០០៨ |
| ១០-វរនាវីឯក | **ទេព** | **ធុទ្ធី** | អត្តលេខ ០១៥០៨៣ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១១-វរនាវីឯក **ឡឹក សាថន** អត្តលេខ ០៩១២២០

១២-វរនាវីឯក **ហាស់ សុទ្ធា** អត្តលេខ ០៤២៧៦៦

**មាត្រា២ៈ** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១៦១១.១០០៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

លេខៈ ៩៩៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១១១៦/ ១១៩៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **ជី សាន** ពីឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មកឋានន្តរសក្តិ **ឧត្តមសេនីយ៍ឆោ** អត្តលេខ ៧៨២២២ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ១១៩១ ស.ណ
សំណៅដែលមានអង្គ្លេចាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រក. ១៦១១. ២០០៩

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/៩៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហាន លូយូ** (HAN LUYOU) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៨០ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ៧. ១៦១១. ១០១០

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

លេខៈ ៩៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/ ៩៩៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ី ឈុយហុង** (XU CUIHONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៦៩ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៨.១៦១១.១០១១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

លេខៈ ៩៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/ ៩៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាកិច្ចបច្ចាមរណៈ**

**ចំពោះ**

សពឯកឧត្តម **ពេជ កែវ**

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

ចាស. ១៥១១-១០១៦
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ...០៤៩/១៦... រវ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ...១០... ខែ វិច្ឆិកា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAL ... LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជ...

# ព្រះរាជក្រឹត្យ

នស/រកត/១១១៦/១០០០

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្ដម **សុខ សូភេន** ជាអនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ៨. ១៦១១.១០១៣

លេខៈ ៩៩៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០៦៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** : ផ្ទេរក្របខ័ណ្ឌលោក **ហង្ស សុខា** ពីក្របខ័ណ្ឌក្រសួងការពារជាតិទៅបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១១៤៣..អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ១០៦៧អនក្រ.តត ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការផ្ទេរក្របខ័ណ្ឌ នាយទាហាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ :** តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **លឹម ផាន់តារៈ** អត្តលេខ ៧៨៩៩៩ ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១១៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **អៀម មុន្នីណារ័ត្ន** អត្តលេខ ០១១១២ ជាអនុប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១១៤៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | **ធឿន** | **វណ្ណារ៉ា** | អត្តលេខ ០៥៦៣១៣ | ជំនួយការ ឯកឧត្តម ម៉ឹង សំផន |
| ២-វរសេនីយ៍ទោ | **ស្រ៊ុន** | **សុខគីម** | អត្តលេខ ០៥០៧២៣ | ជំនួយការ ឯកឧត្តម ម៉ឹង សំផន |
| ៣-វរសេនីយ៍ទោ | **ផន** | **យិនវ៉ាទី** | អត្តលេខ ០៥៣៦៧៥ | ជំនួយការ ឯកឧត្តម ម៉ឹង សំផន |
| ៤-វរសេនីយ៍ទោ | **ស្វ** | **ចាន់** | អត្តលេខ ០០៨៧៩០ | ជំនួយការ ឯកឧត្តម ភួង ស៊ីផាន |
| ៥-វរសេនីយ៍ទោ | **មាស** | **សីលា** | អត្តលេខ ០១២៥៤១ | ជំនួយការ ឯកឧត្តម ឯល វ៉ាន់សារ៉ាត |
| ៦-វរសេនីយ៍ទោ | **ហេង** | **ផាន់ណា** | អត្តលេខ ០១៥៤១៩ | ជំនួយការ ឯកឧត្តម នាង ផាត |
| ៧-វរសេនីយ៍ទោ | **ឌិន** | **រតនា** | អត្តលេខ ០២៥០៦០ | ជំនួយការ ឯកឧត្តម ជៀង អំ |
| ៨-វរសេនីយ៍ទោ | **សុខុន** | **ស្រីល័ក្ខ** | អត្តលេខ ០៣០០៥៦ | ជំនួយការ លោកជំទាវ ដាំ ដារីនី |
| ៩-វរសេនីយ៍ទោ | **ដែន** | **ដាទីត** | អត្តលេខ ១៦៦៤៨៦ | ជំនួយការ ឯកឧត្តម អ៊ុន ដែន |

១០-វរសេនីយ៍ទោ **ពេជ្រ វណ្ណា** អត្តលេខ ០៤៥៧២៧ ជំនួយការ ឯកឧត្តម កែវ តាំ
១១-វរសេនីយ៍ទោ **ថា មុទ្ធា** អត្តលេខ ០២៤៨៥៦ ជំនួយការ ឯកឧត្តម ឡុង តារា
១២-វរសេនីយ៍ទោ **ឡុង មុន្នី** អត្តលេខ ០១៦៦៥៧ ជំនួយការ ឯកឧត្តម នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង
១៣-វរសេនីយ៍ទោ **ដួង ខឿន** អត្តលេខ ០៣៨៨៦៤ នាយរងការិយាល័យស្រាវជ្រាវ និងចងក្រងឯកសារ អគ្គលេខាធិការ នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៤-វរសេនីយ៍ទោ **ឆេង សុធន** អត្តលេខ ០៤០១០៧ ជំនួយការ ឯកឧត្តម អគ្គលេខាធិការ នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៥-វរសេនីយ៍ទោ **ឃិន ធីតា** អត្តលេខ ០៣៤០២៥ នាយរងការិយាល័យហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៦-វរសេនីយ៍ទោ **ម៉ុម សុខវ៉ា** អត្តលេខ ០១៣៧៩៥ ជំនួយការ ឯកឧត្តម ប៉ែន ប៊ុនណារី
១៧-វរសេនីយ៍ទោ **កើត សាវ៉ាត** អត្តលេខ ០៥០៤៩៩ នាយការិយាល័យហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៨-វរសេនីយ៍ទោ **ម៉ៅ ហេង** អត្តលេខ ០១៩៩៧៧ នាយការិយាល័យស្រាវជ្រាវ និងចងក្រងឯកសារ នាយកដ្ឋានហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៩-វរសេនីយ៍ទោ **អ៊ី ម៉ុឡា** អត្តលេខ ០២៨៥២២ នាយលេខាធិការដ្ឋាន នាយកដ្ឋានហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
២០-វរសេនីយ៍ទោ **ហុក សារុំ** អត្តលេខ ០៥៧៦២៥ នាយលេខាធិការដ្ឋាន វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
២១-វរសេនីយ៍ទោ **ឥស្សរ៉ូ សារ៉ែន** អត្តលេខ ០១៤៦២០ នាយលេខាធិការដ្ឋាន នាយកដ្ឋានព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
២២-វរសេនីយ៍ទោ **ឡុង ភួឡាម** អត្តលេខ ០០៣៥៧០ នាយលេខាធិការដ្ឋាន នាយកដ្ឋានគ្រប់គ្រងសារធាតុគីមី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
២៣-វរសេនីយ៍ទោ **ម៉ឺន ណារ៉ា** អត្តលេខ ០៣៥៦១៧ នាយ ការិយាល័យព័ត៌មាន នាយកដ្ឋានព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
២៤-វរសេនីយ៍ទោ **លី អេង** អត្តលេខ ០១៤៥៨៩ មេបញ្ជាការរង កងវិស្វកម្មលេខ១៧៨ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម
២៥-វរសេនីយ៍ទោ **អៀ សុខអៀង** អត្តលេខ ០៤៣៤២២ មេបញ្ជាការរង កងវិស្វកម្មលេខ១៧៨ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម

| | | |
|---|---|---|
| ២៦-វរសេនីយ៍ទោ **នាន់ ប៊ូរ៉េត** | អត្តលេខ ០២៩៨៤០ | មេបញ្ជាការរង កងវិស្វកម្មលេខ១៧៩ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ២៧-វរសេនីយ៍ទោ **ហៀង គីមម៉េង** | អត្តលេខ ០១៤១៩៧ | មេបញ្ជាការរង កងវិស្វកម្មលេខ១៧៩ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ២៨-វរសេនីយ៍ទោ **យុង ទីរាវុឌ្ឍ** | អត្តលេខ ០១៤២០១ | មេបញ្ជាការរង កងវិស្វកម្មលេខ១៨១ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ២៩-វរសេនីយ៍ទោ **ឃុន ច័ន្ទបុណ្ណា** | អត្តលេខ ០១៣៨៥៧ | មេបញ្ជាការរង កងវិស្វកម្មលេខ១៨១ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ៣០-វរសេនីយ៍ទោ **ពុធ វាសនា** | អត្តលេខ ០០១៧៣៥ | មេបញ្ជាការរង កងវិស្វកម្មលេខ១៨២ សំណង់អាគារ នាយកដ្ឋានវិស្វកម្ម |
| ៣១-វរសេនីយ៍ទោ **ថា សុផល** | អត្តលេខ ០១៣៩០៩ | មេបញ្ជាការរង កងវិស្វកម្មលេខ១៨២ សំណង់អាគារ នាយកដ្ឋានវិស្វកម្ម |
| ៣២-វរសេនីយ៍ទោ **សុខ សេរី** | អត្តលេខ ០១៤១៧៤ | នាយការិយាល័យសុរិយោដី នាយកដ្ឋានវិស្វកម្ម |
| ៣៣-វរសេនីយ៍ទោ **សុខ ចំរើន** | អត្តលេខ ០៤៣៥១៩ | នាយការិយាល័យផែនការ នាយកដ្ឋានវិស្វកម្ម |
| ៣៤-វរសេនីយ៍ទោ **ឥន្ទ វណ្ណារិទ្ធ** | អត្តលេខ ១៩៨៨៥០ | នាយការិយាល័យគ្រប់គ្រងអគ្គិសនី ទឹកស្អាត នាយកដ្ឋានវិស្វកម្ម |
| ៣៥-វរសេនីយ៍ទោ **ឡុក ឡេងហួន** | អត្តលេខ ០៤៣៥២១ | នាយការិយាល័យសិក្សាគម្រោង នាយកដ្ឋានវិស្វកម្ម |
| ៣៦-វរសេនីយ៍ទោ **រស់ ស៊ីវណ្ណា** | អត្តលេខ ០០១៥២៦ | នាយលេខាធិការដ្ឋាន កងវិស្វកម្មលេខ ១៧៨ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ៣៧-វរសេនីយ៍ទោ **ខេង សាវុធ** | អត្តលេខ ០០៨៥៨៣ | នាយការិយាល័យស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម |
| ៣៨-វរសេនីយ៍ទោ **ហ៊ឹម ផេន** | អត្តលេខ ០៤៧៨៣០ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺន ភូមិសាស្ត្រយោធា នាយកដ្ឋានភូមិសាស្ត្រ |
| ៣៩-វរសេនីយ៍ទោ **ខិន អោមថារិទ្ធ** | អត្តលេខ ០៥៦៧៦០ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺន ភូមិសាស្ត្រយោធា នាយកដ្ឋានភូមិសាស្ត្រ |
| ៤០-វរសេនីយ៍ទោ **ដួង ច័ន្ទរិទ្ធ** | អត្តលេខ ០៣៦០៥៥ | ជំនួយការ ឯកឧត្តម នាយក មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ |
| ៤១-វរសេនីយ៍ទោ **រស់ សាវុធ** | អត្តលេខ ០១៦៧៧៤ | នាយរងការិយាល័យហិរញ្ញវត្ថុ មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ |
| ៤២-វរសេនីយ៍ទោ **អ៊ឹង ណារិទ្ធ** | អត្តលេខ ០៥៩៦៤១ | ប្រធានគ្រូសីដក់ មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ |

៤៣-វរសេនីយ៍ទោ **ផៃ សុខ** អត្តលេខ ០២៦០៥៨ ប្រធានគ្រូអត្តពលកម្ម មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ

៤៤-វរសេនីយ៍ទោ **អ៊ុំពា សំអាន** អត្តលេខ ០២៦០៥១ គ្រូបាល់ទាត់ មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ

៤៥-វរសេនីយ៍ទោ **ទេព ឡុងរចនា** អត្តលេខ ០២៦០៤៤ គ្រូបាល់ទាត់ មជ្ឈមណ្ឌលកីឡា កងយោធពលខេមរភូមិន្ទ

៤៦-វរសេនីយ៍ទោ **តែម ចាន់កេតនា** អត្តលេខ ០៥៩៦៨៤ លេខា ឯកឧត្តម តែម ម៉ឺន

៤៧-វរសេនីយ៍ទោ **អេង សុគុណា** អត្តលេខ ០០៨៦១៣ ជំនួយការ ឯកឧត្តម ចិន្ត ម៉ារីជូ

៤៨-វរសេនីយ៍ទោ **គីម ធី** អត្តលេខ ០១៦៩០០ នាយការិយាល័យពិសោធន៍វិស្វកម្ម នាយកដ្ឋានស្រាវជ្រាវទិន្នន័យ និងវិស្វកម្ម មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៤៩-វរសេនីយ៍ទោ **ស៊ាង សុខឈន** អត្តលេខ ០៤៥៨៤៨ នាយការិយាល័យគីមី នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៥០-វរសេនីយ៍ទោ **អៀម វណ្ណា** អត្តលេខ ០៣៧៦២១ នាយការិយាល័យពិសោធន៍គុណភាព នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៥១-វរសេនីយ៍ទោ **ឆាយ វ៉ាន់ឆា** អត្តលេខ ២២១២១៣ នាយការិយាល័យសិក្សាស្រាវជ្រាវកាកសំណល់សង្គ្រាម នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៥២-វរសេនីយ៍ទោ **ត្រួយ ស៊ីណាង** អត្តលេខ ១៧៩៤២៥ នាយការិយាល័យស្តង់ដា សម្ភារៈបច្ចេកទេស ជំនាញគ្រប់គ្រងស្តង់ដា សម្ភារៈ និងបច្ចេកទេស មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៥៣-វរសេនីយ៍ទោ **ទាន់ ឥន្ទ្រគិរី** អត្តលេខ ០២៦៧០២ នាយការិយាល័យកំទេចគ្រឿងផ្ទុះ នាយកដ្ឋានផែនការ ប្រតិបត្តិការ និងហ្វឹកហ្វឺន មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

៥៤-វរសេនីយ៍ទោ **គុំ សុខសុផា** អត្តលេខ ០១៤០២២ ប្រធានសាលា នាយកដ្ឋានកិច្ចការយោធាស៊ីវិល អគ្គនាយកដ្ឋានយោធសេវា

៥៥-វរសេនីយ៍ទោ **មិន វរៈ** អត្តលេខ ០៤៣១២៨ នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋានយោធសេវា

៥៦-វរសេនីយ៍ទោ **លី ចាន់សុវណ្ណា** អត្តលេខ ០១៤១០៥ ជំនួយការ ឯកឧត្តម មាស សារ៉ន

៥៧-វរសេនីយ៍ទោ **ស៊ុំ សំអូន** អត្តលេខ ០៥៧៩៧៦ ជំនួយការ ឯកឧត្តម នាង ផែន

៥៨-វរសេនីយ៍ទោ **សួន សុផលមុន្នី** អត្តលេខ ០១៤១១៦ ជំនួយការ ឯកឧត្តម សំ ចាន់ធួន

៥៩-វរសេនីយ៍ទោ **គង់ សុគា** អត្តលេខ ០១៩៨០៩ ជំនួយការ ឯកឧត្តម នាង អេង

៦០-វរសេនីយ៍ទោ **ថាត់ គុណឆាន** អត្តលេខ ១៨៨២០១ ជំនួយការ ឯកឧត្តម សោម ឡាយ

៦១-វរសេនីយ៍ទោ **នឹង សុខ** អត្តលេខ ១៦២៤២៩ នាយការិយាល័យអង្គភាពស្ថាប័នចំណុះ នាយកដ្ឋានអធិការកិច្ច

៦២-វរសេនីយ៍ទោ **គង់ យុវធារី** អត្តលេខ ០២៤៩៨១ នាយការិយាល័យទទួលពាក្យបណ្តឹង នាយកដ្ឋានអធិការកិច្ច

៦៣-វរសេនីយ៍ទោ **សៀន ឆាយ** អត្តលេខ ០១២៤៦៧ ជំនួយការ ឯកឧត្តម នាយក នាយកដ្ឋានអធិការកិច្ច

៦៤-វរសេនីយ៍ទោ **តែម សុទ្ធនន** អត្តលេខ ០២៤៥៨៣ ជំនួយការ ឯកឧត្តម នាយក នាយកដ្ឋានអធិការកិច្ច

៦៥-វរសេនីយ៍ទោ **ហាក្យ ឌិន** អត្តលេខ ០២៤៩៧៩ នាយរងការិយាល័យប្រព័ន្ធច្បាប់ នាយកដ្ឋានអធិការកិច្ច

៦៦-វរសេនីយ៍ទោ **សោម បូរីរក្ស** អត្តលេខ ០៤០២៦១ នាយលេខាធិការដ្ឋាន នាយកដ្ឋានអភិវឌ្ឍន៍

៦៧-វរសេនីយ៍ទោ **ជៀម ធីតា** អត្តលេខ ១៥១៨៤៨ នាយការិយាល័យទំនាក់ទំនងសាធារណៈ នាយកដ្ឋានអភិវឌ្ឍន៍

៦៨-វរសេនីយ៍ទោ **ភាន តិរុន** អត្តលេខ ០៥២៧៤៣ ជំនួយការ ឯកឧត្តម នាយក នាយកដ្ឋានអភិវឌ្ឍន៍

៦៩-វរសេនីយ៍ទោ **ម៉ិច បុណ្ណា** អត្តលេខ ០១៩៧៤៧ ជំនួយការ ឯកឧត្តម នាយក មន្ទីរពេទ្យព្រះកេតុមាលា

៧០-វរសេនីយ៍ទោ **ឈុន សុចិត្ត** អត្តលេខ ១១១៣៤៣ ជំនួយការ ឯកឧត្តម គង់ សាលី

៧១-វរសេនីយ៍ទោ **ឈុន វាន្នី** អត្តលេខ ០២៥២៨៤ នាយឃ្លាំងឱសថ នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

៧២-វរសេនីយ៍ទោ **តៃ យ៉ាត** អត្តលេខ ០៣៩៦៥៩ ជំនួយការ ឯកឧត្តម ទេព សំអាន

៧៣-វរសេនីយ៍ទោ **ឡាច ច័ន្ទដារ៉ា** អត្តលេខ ០១៤៣១៥ ជំនួយការ ឯកឧត្តម ព្រំ សនថុន

៧៤-វរសេនីយ៍ទោ **ម៉ន ប៉ាត់** អត្តលេខ ០២៥៣៣៨ នាយភស្តុភារ ស្ថាប័នអយ្យការយោធា

**រដ្ឋទេយ្យករបុរេប្រទាន** គឺជាអ្នកទទួលខុសត្រូវផ្ទាល់ខ្លួន និងជាប្រាក់កាសនូវការរក្សាមូលនិធិ ដែលខ្លួនទទួលបាន ឬមូលនិធិទាំងឡាយណាដែលបានបុរេប្រទានពីរតនាគារ រក្សាទុកលិខិតយុត្តិការ ព្រមទាំងកាន់កាប់គណនេយ្យប្រតិបត្តិការ។ រដ្ឋទេយ្យករបុរេប្រទានស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន ឬប្រធានអង្គភាពថវិកា ដែលជាអាណាប័កផ្ទេរសិទ្ធិ និងគណនេយ្យករសាធារណៈ ហើយត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ ។

រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើការចំណាយតាមរដ្ឋទេយ្យបុរេប្រទានបានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ត្រូវអនុលោមតាមប្រការ ៩ និង ១០ នៃប្រកាសលេខ ១៩៣៧សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ប្រកាសអន្តរក្រសួង ឬ ដីកាស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទានត្រូវផ្ញើជូនគណនេយ្យករសាធារណៈ និងអភិបាលហិរញ្ញវត្ថុ។

កិច្ចដំណើរការអនុវត្ត និងគ្រប់គ្រងចំណាយតាមរដ្ឋទេយ្យបុរេប្រទានរបស់រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរងត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ៩.-**

**រដ្ឋទេយ្យករចំណូល** ជាអ្នកប្រមូលចំណូលរដ្ឋទេយ្យជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ឬដោយបង្វែរចូលគណនីទោលរបស់រតនាគារ។ រដ្ឋទេយ្យករចំណូលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើរដ្ឋទេយ្យចំណូល។

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន ឬប្រធានអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ និងគណនេយ្យករសាធារណៈ ហើយត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាសចំពោះការរក្សាការពារមូលនិធិដែលខ្លួនទទួលបាន និងការរក្សាទុកលិខិតយុត្តិការ ព្រមទាំងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការរដ្ឋទេយ្យចំណូល។

ការស្នើសុំតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវអនុលោមតាមប្រការ៤ ប្រការ៥ និងប្រការ៦ នៃប្រកាសលេខ ១៨៩០សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យ

ចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចដំណើរការអនុវត្ត និងគ្រប់គ្រងរជ្ជទេយ្យចំណូលរបស់រជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ១០.-**

**ក្រុមលទ្ធកម្ម** គឺជាក្រុមមន្ត្រីរបស់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ដែលត្រូវបានចាត់តាំងសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់អង្គភាពថវិកា ក្នុងកម្រិតឥណទានថវិកា និងសិទ្ធិអំណាចប្រគល់ជូនដោយអាណាប័កដើមខ្សែ។

ក្រុមលទ្ធកម្មដឹកនាំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សាឱ្យប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា។ នីតិវិធីលម្អិតសម្រាប់បង្កើតក្រុមលទ្ធកម្មត្រូវអនុវត្តតាមប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា។

**ប្រការ១១.-**

**ភ្នាក់ងារបើកផ្តល់** គឺជាអ្នកទទួលបន្ទុកជំនួសគណនេយ្យករសាធារណៈក្នុងកិច្ចប្រតិបត្តិការទទួលមូលនិធិសម្រាប់ការចំណាយតាមរយៈគណនីប្រាក់បញ្ញើ ដែលបានបើកនៅអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់ថ្នាក់កណ្តាល ឬនៅរតនាគាររាជធានី ខេត្តសម្រាប់ថ្នាក់មន្ទីជំនាញរាជធានី ខេត្ត។

ភ្នាក់ងារបើកផ្តល់ ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិល្អនិងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិការគណនេយ្យ ដែលអាចគ្រប់គ្រងលើការបើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

## ជំពូកទី៣

## សិទ្ធិអំណាច ការទទួលខុសត្រូវ

## និងនីតិវិធីចំណាយថវិការបស់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ

### ផ្នែកទី១

### សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ១២.-**

អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ មានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម÷

១. ការរៀបចំថវិកា

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមីជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័នសាមី
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាពស្ថិតក្រោមឱវាទ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗទៀតនៃមាតិកាថវិកា
- ចូលរួមការចរចាថវិកាកម្រិតជំនាញ និងកម្រិតថ្នាក់ដឹកនាំតាមការអញ្ជើញរបស់អាណាប័កដើមខ្សែ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីចាំបាច់។

២. ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួន ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានវិភាជន៍ជូនដោយអាណាប័កដើមខ្សែ។
- រៀបចំគម្រោងកម្មវិធីចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសរួចបញ្ជូនមកអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ឱ្យបានទាន់ពេលវេលាកំណត់។
- អនុវត្តតាមកម្មវិធីចំណូល ចំណាយដែលក្រសួង ស្ថាប័នអាណាព្យាបាលកំណត់ឱ្យអនុវត្តតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។
- មានសិទ្ធិពេញលេញក្នុងកិច្ចប្រតិបត្តិការចំណូលរបស់ខ្លួន។
- មានសិទ្ធិពេញលេញក្នុងការរៀបចំ និងអនុវត្តកញ្ចប់រដ្ឋទេយ្យបុរេប្រទាន ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានជាធរមាន។
- មានសិទ្ធិពេញលេញ ក្នុងការស្នើសុំគោលការណ៍ធានាចំណាយ និងស្នើសុំការទូទាត់ ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថ្នាក់កណ្តាល និងទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថ្នាក់រាជធានី ខេត្ត ដើម្បីទទួលការទូទាត់ដោយផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ ឬពីរតនាគាររាជធានី ខេត្ត ដោយត្រូវគោរពទៅតាមក្របខ័ណ្ឌនៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន និងស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។ អង្គភាពថវិកាអាចស្នើសុំការគាំទ្រ និងការសម្របសម្រួលពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្នុងករណីចាំបាច់ ប៉ុន្តែរាល់សំណើសុំធានាចំណាយ និងទូទាត់ត្រូវចម្លងជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីតាមដានការអនុវត្តថវិកា និងបូកសរុបរបាយការណ៍ប្រចាំត្រីមាសឆមាស និងប្រចាំឆ្នាំ។
- អាចស្នើសុំផ្ទេរចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកា ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។

- អាណត្តិបើកប្រាក់ និងអាណត្តិនិយ័តកម្មត្រូវចុះលេខនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។ ឯកសារពាក់ព័ន្ធរួមមាន អាណត្តិបើកប្រាក់ លិខិតស្នើសុំធានាចំណាយ សាលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ដីកាអមបញ្ចេញអាណត្តិបើកប្រាក់ និងដីកាអមលិខិតយុត្តិការត្រូវថតចម្លងជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់ជាកម្មវត្ថុកត់ត្រា បូកសរុប និងតាមដានត្រួតពិនិត្យវាយតម្លៃ។

៣. ការពិនិត្យ និងតាមដានការអនុវត្តថវិកា

- ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទដែលបានកំណត់។

**ប្រការ១៣.-**

អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបង្កើត និងស្នើសុំតែងតាំងដូចខាងក្រោម÷

១. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

២. រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង

៣. រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង

៤. ក្រុមលទ្ធកម្ម

៥. ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស

## ផ្នែកទី២
## នីតិវិធីចំណាយថវិកា

**ប្រការ១៤.-**

ការស្នើសុំគោលការណ៍ធានាចំណាយថវិកា និងការទូទាត់ ត្រូវដាក់ត្រង់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់ សម្រាប់ថ្នាក់រដ្ឋបាលកណ្តាល និងទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការចំណាយតាមបរិបថ ដូចមានក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

អភិបាលហិរញ្ញវត្ថុពិនិត្យ និងសម្រេច រួចបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់ថ្នាក់កណ្ដាល និងទៅរតនាគាររាជធានី ខេត្ត សម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ក្នុងនាមគណនេយ្យករសាធារណៈ ដើម្បីពិនិត្យសម្រេចនិងបើកផ្ដល់សាច់ប្រាក់។

**ប្រការ១៥.-**

រាល់កិច្ចប្រតិបត្តិការគ្រប់គ្រងចំណាយថវិកា ត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ក្នុងនោះមានជាអាទិ៍÷

• ត្រូវគោរពតាមឥណទានថវិកា ដែលបានវិភាជន៍ជូនពីដើមឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី។

• ត្រូវអនុវត្តចំណាយតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលក្នុងនោះបានបែងចែកឥណទានថវិកាទៅតាមខែនីមួយៗនៃឆ្នាំសារពើពន្ធ។ អង្គភាពថវិកាអាចបោះផ្សាយអាណត្តិបើកប្រាក់ក្នុងរង្វង់នៃកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសរបស់ខ្លួន។

• កិច្ចប្រតិបត្តិការចំណាយថវិកាចរន្តត្រូវអនុវត្តតាមប្រភេទចំណាយ និងនីតិវិធីចំណាយដែលរួមមាន÷

- **ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ**: ជាប្រភេទចំណាយតម្រូវឱ្យអនុវត្ត (១)នីតិវិធីចំណាយព្រម និង(២) នីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយមុនបោះអាណត្តិទូទាត់ និង
- **ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ**: ជាប្រភេទចំណាយ ដែលនីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ មុនបោះផ្សាយអាណត្តិទូទាត់។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយក្រុមលទ្ធកម្មរបស់អង្គភាពថវិកាផ្ទាល់ ដោយត្រូវអនុលោមតាមប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា និងតាមការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មជាធរមាន។

• ការទូទាត់ត្រូវបានអនុញ្ញាតក្រោយពេលទំនិញ សំណង់ និងសេវាត្រូវបានត្រួតពិនិត្យ វាយតម្លៃ ឬប្រគល់ ទទួលជាស្ថាពរ។ អង្គភាពថវិកាត្រូវចាត់ចែង និងកំណត់ចំនួនទឹកប្រាក់ចំណាយឱ្យបានច្បាស់លាស់ ហើយត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ទៅតាមចំនួនទឹកប្រាក់ពិតប្រាកដ ដែលត្រូវធ្វើការទូទាត់។

• ការធ្វើចលនាឥណទាន ឬនិយ័តភាពឥណទានអាចអនុវត្តបានចាប់ពីត្រីមាសទី២ នៃឆ្នាំថវិកា ដោយត្រូវអនុលោមតាមនីតិវិធីដូចមានចែងក្នុងគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។ អង្គភាពថវិកាត្រូវពន្យល់អំពីមូលហេតុឱ្យបានត្រឹមត្រូវច្បាស់លាស់ ពីភាពចាំបាច់នៃការធ្វើចលនាឥណទាន ឬនិយ័តភាព

ឥណទាន និងត្រូវធានាថាការអនុវត្តនេះមិនប៉ះពាល់ដល់លទ្ធផលដែលនឹងរួមចំណែកសម្រេចគោលបំណង និងគោលនយោបាយរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៤

## សិទ្ធិអំណាច ការទទួលខុសត្រូវ

## និងនីតិវិធីចំណាយថវិការបស់អង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ

### ផ្នែកទី១

### សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ១៦.-**

អង្គភាពថវិកាមិនមែនជាអាណាប័កផ្ទេរសិទ្ធិ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម÷

១. ការរៀបចំថវិកា

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាពស្ថិតក្រោមឱវាទ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗទៀតនៃមាតិកាថវិកា។
- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័នសាមី។
- ចូលរួមការចរចារថវិកាកម្រិតជំនាញ និងកម្រិតថ្នាក់ដឹកនាំតាមការអញ្ជើញរបស់អាណាប័កដើមខ្សែ ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួន ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានវិភាជន៍ជូនដោយអាណាប័កដើមខ្សែ។
- រៀបចំគម្រោងចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសរួចបញ្ជូនមកអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។
- អនុវត្តកម្មវិធីចំណូល ចំណាយប្រចាំខែ និងប្រចាំត្រីមាសដែលក្រសួង ស្ថាប័នអាណាព្យាបាលបានកំណត់ឱ្យ។
- ទទួលបានសិទ្ធិបញ្ជាចំណាយកញ្ចប់ថវិការដ្ឋទេយ្យបុរេប្រទានតាមការប្រគល់សិទ្ធិដោយអាណាប័កដើមខ្សែ ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានជាធរមាន។
- មានសិទ្ធិស្នើសុំគោលការណ៍ធានាចំណាយ និងការទូទាត់ទៅអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ។

- អាចស្នើសុំផ្ទេរចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកាទៅអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

៣. ការពិនិត្យ និងតាមដានការអនុវត្តថវិកា

- ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ១៧.-**

ដើម្បីអនុវត្តកញ្ចប់ចំណាយរជ្ជទេយ្យបុរេប្រទានតាមការប្រគល់សិទ្ធិដោយអាណាប័កដើមខ្សែ អង្គភាពថវិកា ដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបង្កើតឱ្យមាន÷

១. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

២. រជ្ជទេយ្យករបុរេប្រទានរង

៣. រជ្ជទេយ្យករចំណូលរង

៤. ភ្នាក់ងារបើកផ្តល់ជំនួស

## ផ្នែកទី២
## នីតិវិធីចំណាយថវិកា

**ប្រការ១៨.-**

ការស្នើសុំគោលការណ៍ធានាចំណាយថវិកា និងការទូទាត់ ត្រូវដាក់ជូនអាណាប័កដើមខ្សែតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីសុំហត្ថលេខា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យសម្រេច តាមបរិបថដូចមានក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ១៩.-**

រាល់កិច្ចប្រតិបត្តិការគ្រប់គ្រងចំណាយថវិកា ត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ក្នុងនោះមានជាអាទិ៍÷

- ត្រូវគោរពតាមឥណទានថវិកា ដែលបានវិភាជន៍ជូនពីដើមឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់កម្មវិធី។

- ត្រូវអនុវត្តចំណាយតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលក្នុងនោះបានបែងចែកឥណទានថវិកាទៅតាមខែនីមួយៗនៃឆ្នាំសារពើពន្ធ។
- កិច្ចប្រតិបត្តិការចំណាយថវិកាចរន្តត្រូវអនុវត្តតាមប្រភេទចំណាយ និងនីតិវិធីចំណាយដែលរួមមាន÷
    - **ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ:** ជាប្រភេទចំណាយតម្រូវឱ្យអនុវត្ត (១)នីតិវិធីចំណាយព្រម និង (២) នីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយមុនបោះផ្សាយអាណត្តិទូទាត់ និង
    - **ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ:** ជាប្រភេទចំណាយដែលនីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈមុនបោះផ្សាយអាណត្តិទូទាត់។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់ក្រសួង ស្ថាប័ន ដោយត្រូវអនុលោមតាមនីតិវិធីលទ្ធកម្មជាធរមាន។
- ការទូទាត់ត្រូវបានអនុញ្ញាតក្រោយពេលទំនិញ សំណង់ និងសេវាទាំងឡាយត្រូវបានប្រគល់ ទទួល ឬការងារត្រូវបានសម្រេចរួចហើយ។ ប្រធានអង្គភាពថវិកាត្រូវចាត់ចែង និងកំណត់ចំនួនទឹកប្រាក់ចំណាយឱ្យបានច្បាស់លាស់ ហើយត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ទៅតាមចំនួនទឹកប្រាក់ពិតប្រាកដ ដែលត្រូវធ្វើការទូទាត់។
- ការធ្វើចលនាឥណទាន ឬនិយ័តភាពឥណទានអាចអនុវត្តបានចាប់ពីត្រីមាសទី២នៃឆ្នាំថវិកា ដោយត្រូវអនុលោមតាមនីតិវិធីដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។ អង្គភាពថវិកាត្រូវពន្យល់អំពីមូលហេតុឱ្យត្រឹមត្រូវច្បាស់លាស់ ពីភាពចាំបាច់នៃការធ្វើចលនាឥណទាន ឬនិយ័តភាពឥណទាន និងត្រូវធានាថាការអនុវត្តនេះមិនប៉ះពាល់ដល់លទ្ធផល ដែលនឹងរួមចំណែកសម្រេចគោលបំណង និងគោលនយោបាយរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៥
## កិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍

**ប្រការ២០.-**

អង្គភាពថវិកា ត្រូវមានកិច្ចបញ្ជិកាគណនេយ្យសម្រាប់ប្រតិបត្តិការចំណូល ចំណាយរបស់ខ្លួន ស្របតាមបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

**ប្រការ២១.-**

អង្គភាពថវិកានៃក្រសួង ស្ថាប័នថវិកាកម្មវិធីមានកាតព្វកិច្ចរៀបចំរបាយការណ៍ពីរប្រភេទគឺ (១)របាយការណ៍

ហិរញ្ញវត្ថុ និង (២)របាយការណ៍សមិទ្ធកម្ម ទៅតាមគោលការណ៍ និងទម្រង់ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី និងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ប្រការ២២.-**

របាយការណ៍ហិរញ្ញវត្ថុ វិភាគអំពីស្ថានភាពអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា ដោយបង្ហាញព័ត៌មានអំពីកញ្ចប់ឥណទានថវិកាដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ការធ្វើចលនាឥណទានថវិកា ការប្រើប្រាស់ និងសមតុល្យឥណទានថវិកា ទាំងការធានាចំណាយ ទាំងការបោះផ្សាយអាណត្តិបើកប្រាក់ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិការបស់អង្គភាពថវិកានៃក្រសួង ស្ថាប័ន ដោយអនុលោមទៅតាមទម្រង់តារាងគំរូរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមទម្រង់នៃប្រភេទរបាយការណ៍របស់ក្រសួង ស្ថាប័នសាមី។ របាយការណ៍ហិរញ្ញវត្ថុក៏ត្រូវបង្ហាញអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំសារពើពន្ធ ធៀបជាមួយនឹងលទ្ធផលអនុវត្តនៅឆ្នាំមុនៗ។

អង្គភាពថវិកាត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ រួចផ្ញើមកអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ តាមការិយបរិច្ឆេទដូចខាងក្រោម ៖

- របាយការណ៍ចំណូល ចំណាយប្រចាំខែតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ នៃខែបន្ទាប់។
- របាយការណ៍ចំណាយប្រចាំត្រីមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ នៃខែនៅដើមត្រីមាសបន្ទាប់។
- របាយការណ៍ចំណាយប្រចាំឆមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹម៥ថ្ងៃ បន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ។
- របាយការណ៍ចំណូល ចំណាយសម្រាប់ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ នៃខែកក្កដា។
- របាយការណ៍ចំណូល ចំណាយប្រចាំឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ ខែមករា នៃឆ្នាំបន្ទាប់។
- របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ ខែមករា ឆ្នាំបន្ទាប់។

**ប្រការ២៣.-**

របាយការណ៍សមិទ្ធកម្ម គឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផល និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី ឬកម្មវិធីរបស់អង្គភាពថវិកាក្នុងការរួមចំណែកសម្រេចគោលបំណងគោលនយោបាយ

របស់ក្រសួង ស្ថាប័ន។ អង្គភាពថវិកានៃក្រសួង ស្ថាប័ន ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និងសូចនាករលទ្ធផលចុងក្រោយ ដោយអនុលោមទៅតាមទម្រង់តារាងគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍របស់ក្រសួង ស្ថាប័នសាមី ។

របាយការណ៍សមិទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដូចខាងក្រោម ÷

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស កម្រិតចង្កោមសកម្មភាព និង/ឬ កម្រិតអនុកម្មវិធី ត្រូវផ្ញើមកយ៉ាងយូរបំផុត២០ថ្ងៃ បន្ទាប់ពីបញ្ចប់ការអនុវត្តនៃឆមាសទី១។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដល់កម្រិតកម្មវិធីត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមខែមីនានៃឆ្នាំបន្ទាប់។

**ប្រការ២៤.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពថវិកា ត្រូវស្ថិតក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់សវនកម្មអធិការកិច្ចហិរញ្ញវត្ថុ និងអាជ្ញាធរទាំងឡាយដែលមាននីតិសម្បទាត្រួតពិនិត្យ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**ប្រការ២៥.-**

ប្រធានអង្គភាពថវិកា និងមន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ គ្រប់ឋានៈ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីចំពោះសកម្មភាពក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ។

**ប្រការ២៦.-**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍÷

- ការស្តីបន្ទោស
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័នថវិកាកម្មវិធី "ដើម្បីជូនជ្រាបនិងសហការអនុវត្ត"
- ដូចប្រការ២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១

**បរិបថ និងនីតិវិធីចំណាយថវិការបស់អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ**



ឧបសម្ព័ន្ធ២

**បរិបថ និងនីតិវិធីចំណាយថវិការបស់អង្គភាពថវិកាដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ**

**(សម្រាប់ថ្នាក់រដ្ឋបាលកណ្តាល)**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៥៥៣ ឧស.[illegible].១១

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន រ៉ុន ឆេស្ទ័រ អ៊ីន។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន រ៉ុន ឆេស្ទ័រ អ៊ីន (RONCHESTER INC.) តំណាងដោយ លោក SHINICHI KASUGA បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេស តាយសេង បាវិត សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ វ៉ុន ឆេស្ទ័រ អ៊ីន កម្ពុជា "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ដាច់ចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ហេតុការណ៍អំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**__ប្រការ១១៖__** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**__ប្រការ១២៖__** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**__ប្រការ១៣៖__** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**__ប្រការ១៤៖__** ប្រកាសលេខ ០១២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ របស់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន រ៉ុន ឆេស្វ័រ អ៊ីន ត្រូវចាត់ទុកជានិរាករណ៍។

**__ប្រការ១៥៖__** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**__ប្រការ១៦៖__** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៥៤៤ ឧស.ករ.ររភ.១១

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៦

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ផលិតគ្រឿងសំអាង របស់ក្រុមហ៊ុន តៃគី (ខេមបូឌា) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន តៃគី (ខេមបូឌា) (TAIKI (CAMBODIA) CO., LTD.) តំណាងដោយ លោក **KOJI NAKAMURA** បង្កើតរោងចក្រ ផលិតគ្រឿងសំអាង ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្ភារៈសំអាង | ២០២៣ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតគ្រឿងសំអាង តៃគី (ខេមបូឌា) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤:** ប្រកាសលេខ ៩២៨ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រផលិតគ្រឿងសំអាង របស់ក្រុមហ៊ុន តៃគី (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តព្រះសីហនុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៥៥៤ ឧស.ភ.៣.ស.ក.១១

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន អាវ៉ុនខេម ឯ.ក។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អាវ៉ុនខេម ឯ.ក (AHWONCAM CO., LTD.) តំណាងដោយ លោក KIM YEONSU បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិអំពិលផ្អែម ឃុំបារាយណ៍ ស្រុកពញាឮ ខេត្តកណ្តាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ អាវ៉ុនខេម ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១១៖</u>** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១២៖</u>** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**<u>ប្រការ១៣៖</u>** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**<u>ប្រការ១៤៖</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**<u>ប្រការ១៥៖</u>** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

**<u>ចម្លងជូន៖</u>**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តកណ្តាល "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៥៥៩ ឧស.គ.ក.ក.១១

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន អេវើ ផៅវ័ រ អិនធើណេសិនណល ឯ.ក។

## <u>ស ម្រេ ច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឱ្យក្រុមហ៊ុន អេវើ ផៅវ័ អិនធើណេសិនណល ឯ.ក (EVER POWER INTERNATIONAL CO., LTD.) តំណាងដោយ លោក ឈីវ ជីងធីង បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ដែលមានទីតាំងស្ថិតនៅ ភូមិតាភោគ ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| គ្រឿងបន្សំស្បែកជើង | ១៥២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតគ្រឿងបន្សំស្បែកជើង អេវើ ដៅវ័ រ អិនធើណេសិនណល ឯ.ក"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ពេលវេលាអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

**<u>ចម្លងជូន៖</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ